វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៧ ខែកក្កដា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- លិខិតអនុញ្ញាតិនៅក្នុងវិស័យសំណង់នៅកម្ពុជា មានតម្លៃស្មើទឹកប្រាក់ ០២ ប៊ីលាន ដុល្លារអាមេរិច នៅឆមាសដំបូង ក្នុងឆ្នាំ ២០១៨
- ឱនភាពថវិការបស់ប្រទេសហ្វីលីពីនកើនឡើងនៅឆមាសដំបូង ឆ្នាំ២០១៨ តែនៅមានកម្រិតទាបជាងការរំពឹងទុក
- ប្រធានាធិបតីTrump និងប្រធានសហភាពអឺរ៉ុប ព្រមព្រៀងគ្នាធ្វើការទៅលើលុបចោល ពន្ធ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### លិខិតអនុញ្ញាតិនៅក្នុងវិស័យសំណង់នៅកម្ពុជា មានតម្លៃស្មើទឹកប្រាក់ ២ ប៊ីលាន ដុល្លារអាមេរិច នៅឆមាសដំបូង ក្នុងឆ្នាំ ២០១៨

បើយោងទៅតាមព័ត៌មានចេញផ្សាយដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឆមាសដំបូង នាឆ្នាំ២០១៨នេះ វិស័យសំណង់ចំនួន១,៦៤៣គម្រោង ត្រូវបានផ្តល់សិទ្ធិអនុញ្ញាតិនៅលើទំហំ៥.៤ លាន គីឡូម៉ែត្រការ៉េ និងចំនួនមូលធនសរុបចំនួន២.១ ប៊ីលាន។

ក្នុងចំណោមគម្រោងទាំងនេះ ការវិនិយោគផ្ទាល់បរទេសជាលក្ខណៈឯកជន (FDI) មានចំនួនតែ២១គម្រោងតែប៉ុណ្ណោះ ដែលគ្របដណ្តប់លើផ្ទៃដី ០.៩ លានគីឡូម៉ែត្រការ៉េ ប្រមាណ២០% នៃចំនួនមូលធនសរុបដែលបានផ្តល់ការអនុញ្ញាត។

### តារាងប្រចាំសប្តាហ៍៖ តម្លៃប្រេងសាំងនៅប្រទេសកម្ពុជា និងនៅលើពិភពលោក

តារាងប្រចាំសប្តាហ៍ខាងក្រោមនេះ បង្ហាញពីតម្លៃជាមធ្យមនៃប្រេងសាំងនៅកម្ពុជា និងការប្រៀបធៀបតម្លៃជាមួយប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ និងសកលលោក។

ក្រាហ្វិចបង្ហាញពីតម្លៃជាមធ្យមនៃប្រេងសាំងក្នុង១លីត្រនៅកម្ពុជាដែលបានឡើងពី ៣,៥៩០រៀល (២០០៩) ទៅ ៥,១៨២ រៀល (២០១៤) តែមានការធ្លាក់ចុះពីឆ្នាំ២០១៥មក ដែលតម្លៃមានការឡើងចុះៗ ក្នុងចន្លោះ៣,៥០០ ទៅ៤,០០០ រៀល ក្នុង១លីត្រ។

ទំនោររបស់តម្លៃប្រេងសាំង មានឡើងចុះដូចគ្នាទៅនឹងតម្លៃនៅទីផ្សារសកលលោក ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិកទី២។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយតម្លៃប្រេងសាំងនៅកម្ពុជាមានកម្រិតខ្ពស់ជាងតម្លៃជាមធ្យមនៅក្នុងអាស៊ាន និងតម្លៃជាមធ្យមនៅក្នុងបណ្តាប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម។

### តម្លៃប្រេងសាំងនៅកម្ពុជា




### ...នៅលើពិភពលោក




ប្រភព៖ ក្រសួងពាណិជ្ជកម្ម និងធនាគារពិភពលោក

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូរពាណិជ្ជកម្មដទៃទៀត

### ឱនភាពថវិការបស់ប្រទេសហ្វីលីពីនកើនឡើងនៅឆមាសដំបូង ឆ្នាំ ២០១៨ តែមានកម្រិតទាបជាងការរំពឹងទុក

ឱនភាពថវិការបស់ប្រទេសហ្វីលីពីនសម្រាប់ឆមាសដំបូងនាឆ្នាំ ២០១៨ បានកើនដល់ ១៩៣ ប៊ីលាន ប៉េសូ គឺកើនឡើង២៥% ធៀបនឹងឆមាសដំបូងឆ្នាំមុន ។ ប៉ុន្តែការកើនឡើងក៏នៅតែមានកម្រិតតិចជាងអ្វីដែលបានសន្មតដែរ ព្រោះឱនភាពថវិកាមានការទាបជាងការគ្រោងទុក ២៧% ដោយសារតែចំណូលមានការកើនឡើងជាងការរំពឹងទុក។

បើក្រឡេកទៅមើលតែខែមិថុនា ឱនភាពថវិកាមានចំនួន៥៤.៣ ប៊ីលាន ប៉េសូ ធ្លាក់ចុះ៤០% ពី៩០.៩ប៊ីលាន ប៉េសូ នៅក្នុងខែមិថុនា ២០១៧ ដោយសារមូលហេតុដូចគ្នាគឺមកពីការកំណើនខ្លាំងនៃចំណូល ។

## សេដ្ឋកិច្ចអាមេរិក និងធនាគារសហព័ន្ធ

### ប្រធានាធិបតី Trump និងប្រធានសហភាពអឺរ៉ុប ព្រមព្រៀងគ្នាធ្វើការទៅលើលុបចោលពន្ធ

យោងទៅតាមប្រភពព័ត៌មានCNN លោកប្រធានាធិបតី Trump និងប្រធានសហភាពអឺរ៉ុប លោក Jean-Claude Junger បានឯកភាពគ្នាធ្វើការទៅលើការកាត់បន្ថយពន្ធ និងឧបសគ្គពាណិជ្ជកម្ម កាត់បន្ថយភាពតានតឹង នៅក្នុងការបង្កើតអោយមានសង្គ្រាមពាណិជ្ជកម្ម បន្ទាប់កិច្ចប្រជុំនៅសេតវិមាន។

ថ្មីៗនេះ លោកប្រធានាធិបតីTrump បានព្រមានដាក់ពន្ធ២៥% ទៅលើរថយន្តដែលនាំចូលពីប្រទេសអឺរ៉ុប ហើយអឺរ៉ុបក៏បានឆ្លើយតបជាមួយនឹងការព្រមានរបស់ខ្លួនវិញដែរ។ ប៉ុន្តែ បញ្ហាយកពន្ធនេះហាក់បីដូចជាត្រូវបានដោះស្រាយរួចហើយ។ មិនតែប៉ុណ្ណោះ សហភាពអឺរ៉ុបថែមទាំងបានឯកភាពបង្កើនការបញ្ជាទិញឧស្ម័នរាវធម្មជាតិពីអាមេរិច និងបន្ធូរបន្ថយឧបសគ្គពាណិជ្ជកម្មទៅលើសណ្តែកសៀងអាមេរិច ព្រមទាំងផ្តល់ជំនួយដល់កសិករអាមេរិច និងទៅលើវិស័យថាមពលទៀតផង ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ព័ត៌មាននៅសប្តាហ៍បន្ទាប់រួមមាន ការសម្រេចកំណត់អត្រាការប្រាក់របស់សហរដ្ឋអាមេរិក អត្រាអ្នកគ្មានការងារ និងការសម្រេចកំណត់អត្រាការប្រាក់របស់ប្រទេសជប៉ុន និងអត្រាអតិផរណារបស់ប្រទេសកូរ៉េខាងត្បូង ប្រទេសវៀតណាម និងប្រទេសឥណ្ឌូនេស៊ី ។

ប្រតិទិនខាងក្រោមនេះបង្ហាញពីប្រតិទិនអំពីព័ត៌មានទិន្នន័យ និងការវិវឌ្ឍនានា ដែលក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ នឹងបន្តតាមដាននាសប្តាហ៍បន្ទាប់ ។

<u>ថ្ងៃច័ន្ទ ទី៣០ ខែកក្កដា</u>

- ទិន្នន័យលក់រាយរបស់ប្រទេសជប៉ុន នៅខែមិថុនា
- អត្រាអ្នកគ្មានការងាររបស់ប្រទេសថៃ នៅខែមិថុនា
- អត្រាអតិផរណារបស់ប្រទេសវៀតណាម នៅខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសប្រ៊ុយណេ នៅខែឧសភា
- ទិន្នន័យការលក់ផ្ទះដែលមានស្រាប់ កំពុងបំពេញកិច្ចសន្យា(pending home sales) របស់សហរដ្ឋអាមេរិក នៅខែមិថុនា

<u>ថ្ងៃអង្គារ ទី៣១ ខែកក្កដា</u>

- សូចនាករនៃជំនឿទុកចិត្តរបស់សហគ្រាស(business confidence) របស់ប្រទេសកូរ៉េខាងត្បូង នៅខែមិថុនា
- ទិន្នន័យផលិតកម្មផ្នែកឧស្សាហកម្មរបស់ប្រទេសកូរ៉េខាងត្បូង នៅខែមិថុនា
- អត្រាអ្នកគ្មានការងាររបស់ប្រទេសជប៉ុន នៅខែមិថុនា
- សន្ទស្សន៍គ្រប់គ្រងការទិញរបស់សហគ្រាសផលិត របស់ការិយាល័យស្ថិតិជាតិប្រទេសចិន (National Bureau of Statistics Manufacturing Purchasing Manager Index) នៅខែមិថុនា
- ការសម្រេចកំណត់អត្រាការប្រាក់របស់ធនាគារជាតិប្រទេសជប៉ុន
- ទិន្នន័យផលិតកម្មផ្នែកឧស្សាហកម្មរបស់ប្រទេសថៃ នៅខែមិថុនា

<u>ថ្ងៃពុធ ទី០១ ខែសីហា</u>

- អត្រាអតិផរណារបស់ប្រទេសកូរ៉េខាងត្បូង នៅខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសកូរ៉េខាងត្បូង នៅខែមិថុនា
- អត្រាអតិផរណារបស់ប្រទេសឥណ្ឌូនេស៊ី នៅខែមិថុនា
- ទិន្នន័យការហូរចូលនៃចំនួនអ្នកទេសចរណ៍ នៅខែមិថុនា

<u>ថ្ងៃព្រហស្បតិ៍ ទី០២ ខែសីហា</u>

- ការសម្រេចកំណត់អត្រាការប្រាក់របស់ធនាគារសហព័ន្ធប្រទេសសហរដ្ឋអាមេរិក
- សូចនាករនៃជំនឿទុកចិត្តរបស់សហគ្រាសរបស់ប្រទេសថៃ នៅខែកក្កដា

<u>ថ្ងៃសុក្រ ទី០៣ ខែសីហា</u>

- គណនីចរន្តរបស់ប្រទេសកូរ៉េខាងត្បូង នៅខែមិថុនា
- កំណត់ហេតុកិច្ចប្រជុំគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិប្រទេសជប៉ុន
- តុល្យភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក នៅខែមិថុនា
- សន្ទស្សន៍តម្លៃលក់រាយប្រទេសហ្វីលីពីន នៅខែមិថុនា។

*************************